**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ៧៦២/១៤ ក.អ.ជ.ប្រក

ថ្ងៃអង្គារ ៦ កើត ខែ កត្តិក ឆ្នាំ មមី ព.ស.២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា គ.ស ២០១៤

# ប្រកាស

## ស្តីពី

## ការតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការសម្រាប់គណៈកម្មការត្រួតពិនិត្យ កិច្ចការលទ្ធកម្ម របស់គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទនៅខេត្តរតនគិរី ក្រោមហិរញ្ញប្បទានជំនួយឥតសំណង របស់រដ្ឋាភិបាលជប៉ុន

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងលិខិតលេខ៧៩២៣សហវ.អថ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.**-បង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្ម (PRC) សម្រាប់គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទនៅខេត្តរតនគិរី ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | **សួស គង់** | ជាប្រធាន |
| ២. | ឯកឧត្តម | **ចាន់ ដារ៉ុង** | ជាសមាជិក |
| ៣. | លោក | **ធាន សុម៉ារ៉ា** | ជាសមាជិក |



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២រូប ជាសមាជិក

**ប្រការ ២**.- តែងតាំងគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃ (BEC) ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | លោក | **ខួន តារា** | ប្រធាន |
| ២. | លោក | **សារី សុខុម** | សមាជិក |
| ៣. | លោក | **ឈា វ៉េងហ៊ុយ** | សមាជិក |

**ប្រការ ៣**.- មន្ត្រីរាជការដូចមានក្នុងប្រការ ១ និងប្រការ ២ មានភារកិច្ចទទួលខុសត្រូវ ដឹកនាំ ត្រួតពិនិត្យកិច្ចការលទ្ធកម្មគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទនៅខេត្តរតនគិរី ក្រោមហិរញ្ញប្បទានជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន។

**ប្រការ ៤**.-សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**- នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

<u>កន្លែងទទួល</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ៣*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*

**ជា សុផារ៉ា**